ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA

Kingdom of Wonder

feel the warmth

ក្រសួងទេសចរណ៍

លេខ ៣៤២ សណ.រកទ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការដាក់ឱ្យដំណើរការសាកល្បងកម្មវិធីលក់បញ្ចុះតម្លៃសេវាកម្មទេសចរណ៍ ប្រចាំឆ្នាំ២០២៦ ខេត្តសៀមរាប (2026 Siem Reap Tourism Service Mega Sale )

ក្រសួងទេសចរណ៍មានកិត្តិយសសូមជម្រាបជូន ភ្ញៀវទេសចរជាតិ និងអន្តរជាតិទាំងអស់ មេត្តាជ្រាបថា ដើម្បីចូលរួមជំរុញសកម្មភាពទេសចរណ៍ក្នុងខេត្តសៀមរាបក្នុងរដូវកាលបៃតងឱ្យមានភាពរស់រវើកបន្ថែមទៀត ក្រសួងទេសចរណ៍ ក្រោមកិច្ចសហការជាមួយសមាគមសណ្ឋាគារកម្ពុជាសាខាខេត្តសៀមរាប និងសមាគមក្លឹបទេសចរណ៍ខេត្តសៀមរាប ពិសេសការគាំទ្រពីអាជីវកម្មទេសចរណ៍នានាក្នុងខេត្តសៀមរាប សូមដាក់ឱ្យដំណើរការសាកល្បង "កម្មវិធីលក់បញ្ចុះតម្លៃសេវាកម្មទេសចរណ៍ប្រចាំឆ្នាំ២០២៦ ខេត្តសៀមរាប 2026 Siem Reap Tourism Service Mega Sale" ដោយគ្រោងនឹងដាក់ឱ្យអនុវត្តចាប់ពីថ្ងៃទី១ ខែសីហា ឆ្នាំ២០២៦ តទៅ។ ភ្ញៀវទេសចរជាតិ និងអន្តរជាតិដែលមានបំណងមកទស្សនាកម្សាន្តខេត្តសៀមរាបអាចធ្វើការកក់សេវាកម្មទេសចរណ៍តាមរយៈគេហទំព័រ www.cambodiawonder.com ដោយទទួលបានការបញ្ចុះតម្លៃពិសេសចាប់ពី ១០% ដល់ ៥០% សម្រាប់សេវាកម្មកម្រិតផ្កាយ៣ រហូតដល់ផ្កាយ៥។

អាស្រ័យហេតុនេះ សូម ភ្ញៀវទេសចរជាតិ និងអន្តរជាតិទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងអញ្ជើញទទួលយកសេវាកម្មបញ្ចុះតម្លៃដ៏ពិសេសនេះ ព្រមទាំងចូលរួមផ្សព្វផ្សាយបន្តឱ្យបានទូលំទូលាយ ដើម្បីវិស័យទេសចរណ៍កម្ពុជា។AR

ថ្ងៃ ពុធ ១៥កើត ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៦

ក្រសួងទេសចរណ៍

ដីឡូត៍លេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Website: www.tourism.gov.kh
Telegram: t.me/motgovkh
ទូរស័ព្ទ៖ +៨៥៥ ២៣ ៨៨៩ ៨៩៨
E-mail: admin@tourism.gov.kh